00762681

E154/1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21/12/2011
ម៉ោង (Time/Heure): 15:03
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun


## អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សំណើរបស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ (ឯកសារ E154)

យោងសំណើខាងលើរបស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនត្រូវចម្លងជូនភាគីទាំងអស់នូវរាល់ការប្រាស្រ័យទាក់ទងការងារទាំងឡាយពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។ សំណើសុំនេះធ្វើឡើងបន្ទាប់ពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានផ្ញើលិខិតទៅក្រុមមេធាវីការពារក្តីចំនួន ២ ក្រុម ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មបុគ្គលដែលអាចធ្វើជាសាក្សី ដើម្បីបានដឹងថា តើមេធាវីការពារក្តីពិតជាមានបំណងសួរសំណួរសាក្សីទាំងនេះដែរ ឬយ៉ាងណា ក្នុងករណីដែលសាក្សីទាំងនេះត្រូវបានអង្គជំនុំជម្រះសម្រេចកោះហៅ។ សំណើសុំខាងលើគឺជំទាស់ទៅនឹងការផ្ញើសារអេឡិចត្រូនិកដែលកំហិតត្រឹមតែភាគីមួយចំនួនតូចដោយសំអាងថា "ភាគីដទៃអាចមានបំណងបញ្ចេញយោបល់ពាក់ព័ន្ធនឹងភាគីណាមួយដែលត្រូវសួរសាក្សីណាម្នាក់ ឬពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ" (កថាខណ្ឌ ១២)។

ជាទម្លាប់អនុវត្ត អង្គជំនុំជម្រះសាលាដំបូងតែងតែបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រៀបចំសេចក្តីព្រាងអនុស្សរណៈសម្រាប់អង្គជំនុំជម្រះពិនិត្យពិចារណា ឬអនុម័ត។ អនុលោមតាមទម្លាប់អនុវត្តនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើលិខិតប្រាស្រ័យទាក់ទងការងារដែលមេធាវីការពារក្តីបានលើកឡើង។

អង្គជំនុំជម្រះនឹងប្រគល់ភារកិច្ចទទួលខុសត្រូវក្នុងការសួរសំណួរទៅភាគីដែលបានស្នើសុំកោះហៅសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់តាមការចាំបាច់។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះយល់ថារាល់សេចក្តីសម្រេចទាំងអស់

ពាក់ព័ន្ធទៅនឹងបញ្ហាថាតើអង្គជំនុំជម្រះគួរប្រគល់ភារកិច្ចក្នុងការសួរសំណួរ ឬយ៉ាងណា ហើយគួរប្រគល់ទៅភាគីណាមួយដោយអនុលោមតាមវិធាន៩០នៃវិធានផ្ទៃក្នុងគឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ដែលភាគីពុំអាចជំទាស់បានឡើយ។ ហេតុដូច្នេះ ជាការសមស្របដែលលិខិតប្រាស្រ័យទាក់ទងការងារនោះត្រូវបានមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើទៅភាគីពាក់ព័ន្ធដែលមានរាយនាមក្នុងលិខិតនោះ។

អង្គជំនុំជម្រះធ្វើការកត់សម្គាល់ថា នៅពេលខាងមុខ អង្គជំនុំជម្រះនឹងពុំឆ្លើយតបទៅនឹងសំណើប្រភេទនេះទៀតឡើយ និងអាចចាត់ទុកសំណើប្រភេទនេះថាជាចេតនាព្យាយាមអូសបន្លាយកិច្ចដំណើរការនីតិវិធី។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ទៅភាគីនានាថាពុំចាំបាច់ឆ្លើយតបទៅនឹងសំណើ E154 ឡើយ។ អង្គភាពបកប្រែភាសាត្រូវផ្អាកកិច្ចការបកប្រែឯកសារនានាពាក់ព័ន្ធនឹងសំណើសុំនេះ។

អង្គជំនុំជម្រះក៏សូមរំឭកថាភាគីមិនត្រូវប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយចៅក្រមឡើយ។ ផ្ទុយទៅវិញយន្តការសមស្របសម្រាប់កិច្ចការនេះគឺភាគីត្រូវដាក់សំណើសុំតាមរយៈផ្នែកគ្រប់គ្រងតុលាការ។ ហើយភាគីក៏ពុំត្រូវផ្ញើឯកសារដែលមិនបន្ទាន់នេះក្នុងប្រភេទជា "សេចក្តីជូនដំណឹងក្រៅផ្លូវការជាមុន" នោះឡើយ។ នៅគ្រប់ករណីទាំងអស់ នៅពេលភាគីមានហេតុផលគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាសេចក្តីជូនដំណឹងក្រៅផ្លូវការជាមុនរបស់ខ្លួនគឺជាសេចក្តីជូនដំណឹងបន្ទាន់ ភាគីត្រូវជូនដំណឹងមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងដើម្បីឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងអាចប្រគល់លិខិតជូនដំណឹងនេះជូនចៅក្រម។

ជាមួយគ្នានេះ អង្គជំនុំជម្រះសង្កេតឃើញថាសេចក្តីជូនដំណឹងក្រៅផ្លូវការជាមុនដែលភាគីបានដាក់តែ ១ ភាសា (ដោយសារបញ្ហាជាប់គាំងការបកប្រែភាសា) រមែងខុសប្លែកខ្លាំងពីសេចក្តីជូនដំណឹងដែលភាគីបានដាក់នៅពេលក្រោយមកទៀត។ ចំណុចនេះប៉ះពាល់ដល់ប្រសិទ្ធភាពការងាររបស់ភាគីដទៃទៀត ឬរបស់អង្គជំនុំជម្រះ។ ភាគីដែលបន្តអនុវត្តទម្លាប់មិនត្រឹមត្រូវបែបនេះនឹងត្រូវអង្គជំនុំជម្រះដកហូតឱកាសក្នុងការដាក់សេចក្តីជូនដំណឹង ក្រៅផ្លូវការជាមុនអំពីសំណើរបស់ខ្លួនមកអង្គជំនុំជម្រះ ហើយជាជំនួសវិញអង្គជំនុំជម្រះនឹងតម្រូវឱ្យភាគីដាក់សំណើជាភាសាខ្មែរ និងជាភាសាការងារមួយទៀតនៅ អ.វ.ត.ក ឱ្យបានទាន់ពេលវេលាតាមរយៈផ្នែកគ្រប់គ្រងតុលាការ។